**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ...០០៤/២២...ន.គ.ស គ.ក.គ.ក.

ថ្ងៃ ច័ន្ទ ៤រោច ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែ មីនា ឆ្នាំ២០២២

## សេចក្តីជូនដំណឹង

កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ត្រូវបានដាក់ឱ្យអនុវត្តដោយប្រកាសលេខ៣១៨ សហវ.ប្រក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។ កម្មវិធីសិក្សានេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ហៅកាត់ថា **គ.ក.គ.ក.**។ អនុលោមតាមប្រកាសលេខ០១៣ អសហ.ប្រក ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២ ស្តីពីការគ្រប់គ្រងកម្មវិធីគណនេយ្យករជំនាញកម្ពុជា ជំពូកទី២ ប្រការ៣ សមាសភាពនៃគណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា មានតំណាងបុគ្គលឯករាជ្យក្នុងវិស័យគណនេយ្យនិងសវនករ ចំនួន ០១រូប ជាសមាជិក។ ដូចនេះ **គ.ក.គ.ក.** ត្រូវការជ្រើសរើសបុគ្គលឯករាជ្យដែលជាអ្នកជំនាញគណនេយ្យនិងសវនកម្ម ចូលរួមជាសមាជិកចំនួន០១រូប ដើម្បីរួមចំណែកក្នុងការគ្រប់គ្រងនិងអភិវឌ្ឍកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។ អាស្រ័យហេតុនេះ **គ.ក.គ.ក.** សូមជម្រាបជូនដល់សាធារណៈជនដែលមានចំណេះដឹង និងជំនាញក្នុង វិស័យគណនេយ្យនិងសវនកម្ម ដែលមានបំណងចូលរួមជាសមាជិករបស់ **គ.ក.គ.ក.** សូមអញ្ជើញដាក់ពាក្យស្នើសុំដោយបំពេញតាមលក្ខខណ្ឌដូចជា÷

### ១. លក្ខខណ្ឌគុណវុឌ្ឍិសម្រាប់បេក្ខជន

- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យ ឬហិរញ្ញវត្ថុឡើងទៅ ឬមានសញ្ញាបត្រ វិជ្ជាជីវៈ (CPA, ACCA ឬ CA)
- មានបទពិសោធន៍ខាងផ្នែកគណនេយ្យ, ហិរញ្ញវត្ថុ, សវនកម្ម, ឬខាងអប់រំផ្នែកធុរកិច្ច យ៉ាងតិច ៧ ឆ្នាំ

### ២. សំណុំបែបបទដែលត្រូវបំពេញ និងឯកសារភ្ជាប់

- ពាក្យស្នើសុំ (Cover Letter)
- ប្រវត្តិរូបសង្ខេប (Curriculum Vitae)
- សញ្ញាបត្រថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ
- ឯកសារពាក់ព័ន្ធផ្សេងៗ (ករណីចាំបាច់)



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៩៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

## ៣. កាលបរិច្ឆេទ និងទីកន្លែងដាក់ពាក្យ

- កាលបរិច្ឆេទដាក់ពាក្យចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២វេលាម៉ោង៥:០០នាទីល្ងាច។
- ទីកន្លែងដាក់ពាក្យ និយ័តករគណនេយ្យនិងសវនកម្ម អគារ “ក” ជាន់ទី១ ក្នុងបរិវេណ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬសារអេឡិចត្រូនិច(Email) : m.sereyratana@acar.gov.kh ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងតាមរយៈលេខទូរស័ព្ទ ០៩៥ ៨៨៨ ០៩៨។

**គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា**

**ឌី_តាយី**